**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមព្រហ្មទណ្ឌ**
លេខ: ២៤៣៣ "ឈ១"
ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២
សំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៤៨
ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ ៣២៥៥
ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១

## គោរពនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

កាលបរិច្ឆេទបើកសវនាការ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង១៤ និង ៣០នាទី រសៀល នៅសាលសវនាការទី១ ដែលមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី **ទិត ដាលីន** ចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក **សាយ ណូរ៉ា** ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក **ឈិន សេង** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៤៨ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ:

១-ឈ្មោះ **ប៊ុន រតន៍លីដា** ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ប្រធានក្រុមហ៊ុន British American Tobacco (Cambodia) Ltd មានទីកន្លែងកំណើតនៅសង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ២៤ ផ្លូវជាតិលេខ១ បុរីហាយធិច សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ឈិត ចាប់ប៊ុន** "រស់" ម្ដាយឈ្មោះ **លៀង ច័ន្ទមុន្នីរតន៍** "រស់" ប្ដីឈ្មោះ **ចាប ចាន់រស្មី** មានកូនចំនួន០២នាក់ ជានីតិជនទោសពីមុន "គ្មាន" (ក្រៅឃុំ)។

២-ក្រុមហ៊ុន British American Tobacco (Cambodia) Ltd មានអាសយដ្ឋានចុះបញ្ជីនៅផ្ទះលេខ១១២១ ផ្លូវជាតិលេខ២ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-មានលោកមេធាវី **អ៊ុំ រតនា** អត្តលេខ៨៥៦ ,លោកមេធាវី **ស៊ិន សុផាត** អត្តលេខ ១៩៧៧ និងលោកមេធាវី **សួស វិទ្យា** អត្តលេខ២១៦៦T មានការិយាល័យនៅអគារ ECC លេខ៧២៤ ជាន់ទី២១ យូនីត H មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ជាមេធាវីការពារសិទ្ធិឲ្យក្រុមហ៊ុន British American Tobacco (Cambodia) Ltd។

ជាប់ចោទពីបទ **ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ០៩ ,មាត្រា ១១ ,មាត្រា ៣៩ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

-ដើមបណ្តឹងរដ្ឋប្បវេណី **ក្រសួងសុខាភិបាល** មានអាយដ្ឋាននៅដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ តំណាងស្របច្បាប់ដោយ ឯកឧត្តមវេជ្ជបណ្ឌិត **អ៊ឹង ភីរុន** ជារដ្ឋលេខាធិការក្រសួងសុខាភិបាល។

-មានលោកមេធាវី **លឹម ស៊ីម** អត្តលេខ៥៩១ ,លោកមេធាវី **ខៀវ វ៉ាន** អត្តលេខ៣៧៤ ,លោកមេធាវី **គីម វឌ្ឍនៈ** អត្តលេខ១៨៨៦T និងលោកមេធាវី **សែម ស៊ីនរិទ្ធ** អត្តលេខ១៨៨៣T មានការិយាល័យនៅបន្ទប់លេខ៤២ ,២៣F អគារ The Bridge-SOHO ផ្លូវរដ្ឋសភាជាតិ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិឱ្យក្រសួងសុខាភិបាល។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ ក្រុមហ៊ុន British American Tobacco Cambodia Ltd មានអាសយដ្ឋានចុះបញ្ជីនៅផ្ទះលេខ១១២១ ផ្លូវជាតិលេខ២ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានឈ្មោះ **ប៊ុន រតន៍លីដា** ភេទសី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ ជាប្រធានក្រុមហ៊ុន បានធ្វើសកម្មភាពផ្សព្វផ្សាយនូវផលិតផលថ្នាំជក់របស់ខ្លួននៅទីសាធារណៈ តាមរយៈការដាក់ផ្ទាំងរូបភាពបង្ហាញពីផលិតផលរបស់ខ្លួន ហើយក្រុមហ៊ុនក៏បានលើកកម្ពស់ការផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយបានបោះពុម្ពនៅលើអាវភ្នាក់ងារលក់របស់ខ្លួន និងឱ្យបុគ្គលិកចុះទៅផ្សព្វផ្សាយតាមភោជនីយដ្ឋាន និងទីសាធារណៈ ព្រមទាំងបានធ្វើការប្រគុំតន្ត្រីមានការផ្តល់រង្វាន់ដល់អតិថិជនរបស់ខ្លួន ម្យ៉ាងវិញទៀតក្រុមហ៊ុនក៏បានប្រើប្រាស់ពាក្យទាក់ទាញ និងធ្វើឱ្យយល់ច្រឡំដូចជា រក្សាក្លិន និងគុណភាពបានល្អថែមទៀតផង។ លុះដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ ក្រសួងសុខាភិបាលក៏បានដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល តំណាងដោយឯកឧត្តមវេជ្ជបណ្ឌិត **អ៊ឹង ភីរុន**។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: **០៨៥ អ.យ.ន** ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌរបៀបលេខ ១៦២ “ឈ១” ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: **០៥៦ អ.យ.ឃ** ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ **ប៊ុន រតន៍លីដា** នៅដំណាក់កាលអយ្យការ បានឆ្លើយថា: ចំពោះការលើកឡើងរបស់ក្រសួងសុខាភិបាលដែលបានចោទប្រកាន់ក្រុមហ៊ុនរបស់ខ្លួនថា បានឱ្យបុគ្គលិកចុះធ្វើការផ្សព្វផ្សាយផលិតផលបារីម៉ាក៥៥៥ នៅទីសាធារណ:នោះ គឺមិនពិតប្រាកដឡើយ ដោយសាររូបភាពបុគ្គលិករបស់ក្រុមហ៊ុនខ្លួនដែលមាននៅក្នុងភស្តុតាងនេះ មិនមែនជាបុគ្គលិកចុះផ្សព្វផ្សាយនោះឡើយ គឺជាភ្នាក់ងារលក់របស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយឯកសណ្ឋានរបស់បុគ្គលិកទាំងអស់នោះក៏មិនបានបង្ហាញអំពីរូបភាពផលិតផលបារី ដែលធ្វើឱ្យមានការទាក់ទាញដល់សាធារណ:ជននោះឡើយ។ ចំពោះការប្រគល់រង្វាន់ ខ្លួនទទួលស្គាល់ថាក្រុមហ៊ុនពិតជាបានប្រគល់រង្វាន់ដល់អតិថិជនប្រាកដមែន ប៉ុន្តែអតិថិជនទាំងអស់នោះគឺជាអ្នកលក់បោះដុំនូវផលិតផលរបស់ក្រុមហ៊ុនខ្លួនតែប៉ុណ្ណោះ មិនមែនជាការផ្តល់រង្វាន់ដល់អ្នកប្រើប្រាស់ផ្ទាល់ឡើយ ចំណែកការប្រគុំតន្ត្រីដូចមាននៅក្នុងរូបភាពជាភស្តុតាងនោះ គឺគ្រាន់តែជាពិធីជប់លៀងលើកទឹកចិត្តដល់អតិថិជនទទួលបោះដុំពីក្រុមហ៊ុន ហើយការរៀបចំនេះក៏គ្រាន់តែជាការជួបជុំជាលក្ខណ:ឯកជនរបស់ក្រុមហ៊ុនស្ថិតក្នុងទីតាំងបិទជិតដោយមានការចូលរួមពីដៃគូសហការ និងអ្នកលក់បោះដុំពុំមែនធ្វើឡើងជាសាធារណ:នោះទេ។ ក្នុងរឿងនេះក្រុមហ៊ុនរបស់ខ្លួនមិនធ្លាប់ទទួលបានលិខិតអញ្ជើញដើម្បីចូលរួមដោះស្រាយ ឬលិខិតព្រមានពីក្រសួងសុខាភិបាលឡើយ ចំណែកអាជ្ញាធរមានសមត្ថកិច្ចក៏មិនបានធ្វើការដកហូតផលិតផលរបស់ក្រុមហ៊ុននោះដែរ ហើយកន្លងមកក្រុមហ៊ុនរបស់ខ្លួនតែងតែគោរពតាមច្បាប់តឹងតែងបំផុត ដែលជាហេតុមិនដែលមានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យ និងដកហូតផលិតផលរបស់ក្រុមហ៊ុនខ្លួនឡើយ ដោយសារតែផលិតផលមានច្បាប់អនុញ្ញាតត្រឹមត្រូវ ហើយការផលិត និងការវេចខ្ចប់សុទ្ធតែគោរពទៅតាមការកំណត់របស់ច្បាប់ទាំងអស់ដូចជាការដាក់រូបភាពបង្ហាញពីផលប៉ះពាល់លើកញ្ចប់បារី និងសារព្រមានជាដើម ចំណែកឯផលិតផលដែលមានដាក់សារព្រមានជាភាសារអង់គ្លេស (SMOKING KILLS) គឺជាផលិតផលក្លែងក្លាយ ហើយក្រុមហ៊ុនរបស់ខ្លួនក៏បានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការតាមច្បាប់រួចរាល់អស់ហើយ។ ចំពោះភស្តុតាងជារូបភាពដែលបង្ហាញអំពីពាក្យទាក់ទាញដូចជាពាក្យថា "ភាពស្រស់ស្រាយ នៃរស់ជាតិរបស់កម្ពុជា ,ចុចកន្ទុយបារីដើម្បីបង្កើតភាពស្រស់ស្រាយ និងរសជាតិនៃភាពស្រទន់" នៅលើទូលក់បារី និងក្រដាស់ចងខ្សែ ដូចមានក្នុងពាក្យសុំបញ្ចូលភស្តុតាង ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់លោកមេធាវី **សែម ស៊ីនរិទ្ធិ** និងលោកមេធាវី **កឹម វឌ្ឍនៈ** ជាមេធាវីការពារក្តី និងតំណាងដោយអាណត្តិឱ្យក្រសួងសុខាភិបាលនោះ គឺជាសម្ភារ:របស់ក្រុមហ៊ុន ហើយក្រុមហ៊ុនបានប្រគល់សម្ភារ:ទាំងអស់នេះដល់អតិថិជនលក់រាយ ប៉ុន្តែការដាក់ពាក្យទាំងអស់នេះ គឺមានតែនៅលើទូលក់បារី និងក្រដាសចងខ្សែប៉ុណ្ណោះ មិនបានដាក់នៅលើផលិតផលរបស់ក្រុមហ៊ុនឡើយ និងពុំមានបង្ហាញម៉ាកយីហោរបស់ផលិតផលឡើយ។

-ក្រឡាបញ្ជីអានពាក្យបណ្តឹងរបស់ក្រសួងសុខាភិបាល ដែលតំណាងស្របច្បាប់ដោយ ឯកឧត្តមវេជ្ជបណ្ឌិត **អ៊ុង ភីរុន** ជារដ្ឋលេខាធិការក្រសួងសុខាភិបាល បានបញ្ជាក់ថា: កន្លងមកក្រុមហ៊ុន British American Tobacco (Cambodia) Ltd. ដែលជាក្រុមហ៊ុនលក់ផលិតផលថ្នាំជក់ បានធ្វើការផ្សព្វផ្សាយផលិតផលថ្នាំជក់របស់ខ្លួននៅទីសាធារណៈ ជាលក្ខណៈផ្ទាំងរូបភាពពាណិជ្ជកម្មនៃផលិតផលថ្នាំជក់ ដែលបោះពុម្ពនៅលើអាវរបស់ភ្នាក់ងារបុគ្គលិករបស់ខ្លួន។ មិនតែប៉ុណ្ណោះក្រុមហ៊ុននេះ បានធ្វើការលើកកម្ពស់ការផ្សព្វផ្សាយផលិតផលថ្នាំជក់ដល់អតិថិជន ដោយក្រុមហ៊ុននេះបានឱ្យភ្នាក់ងារបុគ្គលិកពាក់អាវដែលមានផ្ទាំងរូបភាពនោះ ចុះទៅផ្សព្វផ្សាយតាមភោជនីយដ្ឋាន និងទីសាធារណៈ ដែលជាសកម្មភាពត្រូវបានហាមឃាត់ក្នុងការផ្សព្វផ្សាយផលិតផលថ្នាំជក់។ ម្យ៉ាងទៀតក្រុមហ៊ុននេះក៏បានធ្វើការផ្សព្វផ្សាយផលិតផលរបស់ខ្លួនតាមរយៈការប្រគុំតន្ត្រី និងមានការផ្តល់រង្វាន់ដូចជា ទូរស័ព្ទដៃថែមទៀតផង ដែលការផ្សព្វផ្សាយក្នុងកម្មវិធីជាសាធារណៈបែបនេះ គឺច្បាប់ពុំអនុញ្ញាតជាដាច់ខាត។ ក្រសួងសុខាភិបាលក៏បានធ្វើការព្រមានក្រុមហ៊ុននេះរួចហើយដែរ ប៉ុន្តែក្រុមហ៊ុននេះនៅតែមិនគោរពតាមច្បាប់ និងការព្រមានរបស់ក្រសួងសុខាភិបាលទៀត។ យោងតាមសកម្មភាពខាងលើ គឺក្រុមហ៊ុននេះមានចេតនាទុច្ចរិតក្នុងការផ្សព្វផ្សាយផលិតផលរបស់ខ្លួន ដើម្បីទទួលបានការចាប់អារម្មណ៍ពីអ្នកប្រើប្រាស់ឱ្យកាន់តែច្រើនដើម្បីទទួលបានផលប្រយោជន៍ឯកជនដោយមិនគិតពីច្បាប់។ សកម្មភាពដែលក្រុមហ៊ុននេះបានប្រព្រឹត្ត ជាសកម្មភាពដែលបំពាននូវច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ហើយការផ្សព្វផ្សាយបែបនេះអាចជម្រុញឱ្យមានការប្រើប្រាស់ថ្នាំជក់កាន់តែច្រើន និងអាចនាំឱ្យមានផលប៉ះពាល់ដល់សុខភាពប្រជាជន និងសុខភាពសាធារណៈដែលច្បាប់ព្យាយាមការពារផងដែរ។

-លោក **ខៀវ វ៉ា** ,លោក **លឹម ស៊ីម** ,លោក **សែម ស៊ីនរិទ្ធ** និងលោក **កឹម វឌ្ឍនៈ** ជាមេធាវីតំណាងឱ្យក្រសួងសុខាភិបាល បានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង ឃើញថា ក្រសួងសុខាភិបាលបានប្តឹងទៅលើក្រុមហ៊ុន British American Tobacco (Cambodia) Ltd. ដែលគាត់បានប្រព្រឹត្តសកម្មភាពកាលពីអំឡុងឆ្នាំ២០១៩-២០២០ ទៅលើសកម្មភាពជាច្រើនពាក់ព័ន្ធនឹងផ្សព្វផ្សាយផលិតផលថ្នាំជក់របស់ខ្លួនជាសាធារណៈ និងនៅតាមភោជនីយដ្ឋាន និងមានលក្ខណៈជាផ្ទាំងរូបភាពពាណិជ្ជកម្មនៃផលិតផលថ្នាំជក់បោះពុម្ពនៅលើអាវរបស់ភ្នាក់ងារបុគ្គលិករបស់ខ្លួន មិនតែប៉ុណ្ណោះថែមទាំងមានការផ្តល់រង្វាន់ជាទូរស័ព្ទដៃទៀតផង ហើយក្រសួងសុខាភិបាលក៏បានធ្វើការព្រមានទៅក្រុមហ៊ុនអំពីសកម្មភាពខាងលើថាជាកម្មភាពខុសច្បាប់ ប៉ុន្តែក្រុមហ៊ុននៅតែមិនគោរពច្បាប់ និងមិនទទួលយកការព្រមានរបស់ក្រសួងសុខាភិបាលទៀតផង នៅក្នុងនេះគាត់បានប្រព្រឹត្តជាច្រើនខុសពីច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។ ចំពោះភស្តុតាងមានការបោះពុម្ព ស្ទីកឃ័រ ជាទូទៅគឺក្រុមហ៊ុនជាអ្នកផលិត ជាអ្នកចែកចាយឱ្យអ្នកលក់មិនគិតថ្លៃ ជាការលើកទឹកចិត្តដល់អ្នកលក់ ដើម្បីឱ្យគាត់ប្រឹងលក់ ហើយជាពិសេសតាមខ្ទង់លក់បារី អានឹងហើយដែលជាកម្មភាពបង្ហាញនូវការលើកទឹកចិត្ត និងជំរុញឱ្យមានការប្រើប្រាស់បារីដែលត្រូវបាន

ច្បាប់ហាមឃាត់។ ចំពោះសកម្មភាពបទល្មើសដែលក្រុមហ៊ុនបានប្រព្រឹត្ត គឺច្បាប់បានចេញមុនសកម្មភាពរបស់ក្រុមហ៊ុន រួចហើយក្រោយពេលដែលច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ចេញរួច ខាងក្រសួងសុខាភិបាលបានធ្វើការជូនដំណឹងទៅឲ្យខាងក្រុមហ៊ុន ដើម្បីឲ្យក្រុមហ៊ុនអនុវត្តតាមច្បាប់ ប៉ុន្តែក្រុមហ៊ុនអនុវត្តទេ ជាក់ស្តែងដូចភស្តុតាងដែលខ្ញុំបាទបានដាក់ជូនតុលាការស្រាប់ គឺក្រសួងបានធ្វើការជូនដំណឹងទៅក្រុមហ៊ុន០៣ដង ជាការព្រមានសុំឲ្យបញ្ឈប់សកម្មភាពផ្សេងៗទាំងឡាយណាដែលផ្ទុយនឹងច្បាប់ ដូចមានចែងក្នុងមាត្រាច្បាប់ ប៉ុន្តែក្រុមហ៊ុនមិនស្តាប់ទាល់តែសោះ ដែលនេះជាសកម្មភាពល្មើសច្បាប់ ទោះបីគាត់អះអាងយ៉ាងណាក៏ដោយ ប៉ុន្តែសកម្មភាពបានកើតឡើងរួចទៅហើយ បទល្មើសបានកើតឡើងរួចទៅហើយ ហើយខាងក្រុមហ៊ុនក៏មិនព្រមធ្វើកិច្ចសន្យាបញ្ឈប់នោះដែរ ហេតុនេះហើយ ក្នុងនាមខាងក្រសួងសុខាភិបាល ស្នើសុំឲ្យតុលាការមេត្តាពិចារណា និងសំណូមពរសុំឲ្យតុលាការផ្តន្ទាទោសទៅលើក្រុមហ៊ុន British American Tobacco (Cambodia) Ltd. និងអ្នកតំណាង ព្រមទាំងបក្ខពួក តាមច្បាប់ឲ្យបានធ្ងន់ធ្ងរ ,ទាមទារសំណងជំងឺចិត្តចំនួន ៤០លានរៀលចូលជាថវិការដ្ឋ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងការពិនិត្យភស្តុតាង ឃើញថា កាលពីអំឡុងឆ្នាំ២០១៩-២០២០ ក្រុមហ៊ុន British American Tobacco (Cambodia) Ltd. បានធ្វើការផ្សព្វផ្សាយផលិតផលថ្នាំជក់របស់ខ្លួនដោយធ្វើការផ្សព្វផ្សាយជាសាធារណៈនូវផលិតផលថ្នាំជក់របស់ខ្លួននៅតាមទីសាធារណៈ និងនៅតាមភោជនីយដ្ឋាន និងមានលក្ខណៈជាផ្ទាំងរូបភាពពាណិជ្ជកម្មនៃផលិតផលថ្នាំជក់បោះពុម្ពនៅលើអាវរបស់ភ្នាក់ងារបុគ្គលិករបស់ខ្លួន មិនតែប៉ុណ្ណោះថែមទាំងមានការផ្តល់រង្វាន់ជាទូរស័ព្ទដៃទៀតផង ហើយក៏មានការប្រគំតន្ត្រីទៀតផង ហើយខាងក្រសួងក៏បានធ្វើការព្រមានពីផលប៉ះពាល់ដែរ ប៉ុន្តែខាងក្រុមហ៊ុនមិនស្តាប់នោះទេ។ ក្នុងនាមតំណាងអយ្យការ សុំតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ **០៥៦ អ.យ.ឃ** ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ ទុកនៅដដែល និងសុំឲ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-លោក **អ៊ុំ រតនា** និងលោក **សួស វិទ្យា** ជាមេធាវីការពារសិទ្ធិជនជាប់ចោទក្រុមហ៊ុន British American Tobacco (Cambodia) Ltd. ដែលមានឈ្មោះ **ប៊ុន រតន៍លីដា** ជាប្រធានក្រុមហ៊ុន បានធ្វើសេចក្តីសន្និដ្ឋានថា: **១-អំពីអង្គហេតុ:** កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ ឯកឧត្តមវេជ្ជ **ម៉ឹង ភីរុន** តំណាងឱ្យក្រសួងសុខភិបាល ដែលបានដាក់ពាក្យបណ្តឹងចោទប្រកាន់កូនក្តីយើងខ្ញុំបាទ BRITISH AMERICAN TOBACCO (CAMBODIA) LIMITED នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីបទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ១១ ,មាត្រា ១៣ ,មាត្រា ៤១ និងមាត្រា ៤៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៤៨ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ តំណាងអយ្យការបានធ្វើការចោទប្រកាន់កូនក្តីយើងខ្ញុំ តាម

មាត្រា ៨ ,មាត្រា ១០ ,មាត្រា ១១ ,មាត្រា ៣៨ ,មាត្រា ៤០ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ និងបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ដោយពុំមានការចូលរួមបំភ្លឺពីភាគីក្រុមហ៊ុនឡើយ។ **២-ធាតុផ្សំនីត្យានុកូលៈ** ក-យោងតាមមាត្រា ៩ បានបញ្ញត្តិថា "ការប្រើប្រាស់ពាក្យដែលទាក់ទាញ និងធ្វើឲ្យយល់ច្រឡំជាអាទិ៍ ក្លិនឈ្ងុយឆ្ងាញ់ រសជាតិស្រាល រសជាតិស្រាលស្រទន់ រសជាតិវីតាមីន កាហ្វេអ៊ីនក្នុងផលិតផលថ្នាំជក់ត្រូវហាមឃាត់"។ តាមរយៈខ្លឹមសារ និងស្មារតីនៃមាត្រានេះ គឺហាមឃាត់ចំពោះការប្រើពាក្យទាក់ទាញចំណីអារម្មណ៍របស់អ្នកប្រើប្រាស់ ដោយបោះពុម្ពនៅលើកញ្ចប់ផលិតផលថ្នាំជក់។ មាត្រា ៩ នេះត្រូវប្រើប្រាស់នៅពេលដែលមានការបោះពុម្ពពាក្យពេជន៏ទាំងនោះនៅលើផលិតកញ្ចប់ផលិតផលថ្នាំជក់ ដូចច្បាប់ដែលបានចែងតែប៉ុណ្ណោះ ដូចនេះ មាត្រា ៩ នេះមិនអាចយកប្រើប្រាស់ដើម្បីហាមឃាត់ការប្រើប្រាស់ពាក្យពេជន៍ទាំងអស់នោះ ដែលមិនបានប្រើប្រាស់បោះពុម្ពនៅលើកញ្ចប់ផលិតផលនោះទ។ ដូចនេះ មាត្រា ៩ នេះមិនអាចប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃនៅលើពាក្យពេជន៍ ដែលប្រើប្រាស់នៅលើខិតប័ណ្ណ ស្ទីកន័រ ផ្ទាំងផ្សព្វផ្សាយ ឬសម្ភារៈសម្រាប់ផ្តល់ដំណឹងអំពីព័ត៌មានផលិតផលថា តើត្រូវអនុញ្ញាត ឬមិនអនុញ្ញាតឲ្យបើនោះទ? ខ-នៅលើគ្រប់កញ្ចប់ផលិតផលថ្នាំជក់ទាំងអស់របស់ក្រុមហ៊ុន BRITISH AMERICAN TOBACCO (CAMBODIA) LIMITED ដែលជាកូនក្តីរបស់យើងខ្ញុំពុំមានប្រើប្រាស់នូវពាក្យពេជចន៍ណាមួយដែលហាមឃាត់ដោយមាត្រា ៩ នៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំជក់ឡើយ។ គ-យោងតាមមាត្រា ១០ នៃច្បាប់ស្តីពីការត្រួតផលិតផលថ្នាំជក់ បានបញ្ញត្តថា "ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទ សម្រាប់ធ្វើការចែកចាយលក់និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលថ្នាំជក់។ សារព្រមានសុខភាពជារូបភាពត្រូវមានទំហំ៥០ (ហាសិប) ភាគរយយ៉ាងតិច។ ការបោះពុម្ពសារព្រមានសុខភាពជាអក្សរ និងរូបភាព ត្រូវកំណត់ដោយអនុក្រឹត្យ។" ចំពោះផលិតផលបារីស្របច្បាប់ គឺបន្ថែមពីលក្ខខណ្ឌនៃការបោះពុម្ពសារព្រមានសុខភាពជារូបភាពទំហំ ៥០% ភាគរយ និងសារព្រមានសុខភាពអក្សរទំហំ៥% គឺត្រូវមានបិទតែមប្រ៍អាករនៅលើកញ្ចប់បារី ដែលតែមប្រ៍អាករនេះ ស្ថិតក្រោមសមត្ថកិច្ចគយ និងរដ្ឋាករ ចំពោះផលិតផលបារីនាំចូល ហើយស្ថិតនៅក្រោមសមត្ថកិច្ចអគ្គនាយកដ្ឋានពន្ធដារសម្រាប់ផលិតផលបារីផលិតក្នុងស្រុក ។ ក្នុងករណីដែលផលិតផលបារីនាំចូលដែលមិនមានបិទតែមប្រ៍នៅលើកកញ្ចប់បារីនោះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករមិនអនុញ្ញាតអោយនាំចូលនោះទ។ ក្រុមហ៊ុន BRITISH AMERICAN TOBACCO (CAMBODIA) LIMITED គឺជាក្រុមហ៊ុនដែលទទួលស្គាល់ថាដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករជាធុរៈជន ដែលមានអនុលោមភាពខ្ពស់តាំងពីឆ្នាំ ២០១៤ មកម្លេះ។ ដូចនេះប្រសិនបើការនាំចូលផលិតផលរបស់ក្រុមហ៊ុនពុំមានបោះពុម្ពផ្សាយនូវសារព្រមានសុខភាពតាមច្បាប់ជាធរមាននោះ គឺអគ្គនាយកដ្ឋានគយ និងរដ្ឋាករនឹងមិនទទួលស្គាល់ជាជាធុរៈជន ដែលមានអនុលោមភាពខ្ពស់ឡើយ។ លើលពីនេះទៅទៀត ផលិតផលដែលមិនមានសារព្រមានសុខភាព ជាភាសារ

អង់គ្លេសនេះជាផលិតផលក្លែងក្លាយគេចពន្ធ ដែលក្រុមហ៊ុន BRITISH AMERICAN TOBACCO (CAMBODIA) LIMITED និងសមាគមថ្នាំជក់កម្ពុជា គឺបានសុំអន្តរាគមន៍ជាញឹកញាប់ទៅស្ថាប័នសមត្ថកិច្ចពាក់ព័ន្ធ ដូចជាអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។ ជាលទ្ធផលនៃការស្នើសុំនេះ គឺមានការចាត់វិធានការពីនគរបាលសេដ្ឋកិច្ច នៃក្រសួងមហាផ្ទៃលើផលិតផលថ្នាំជក់ក្លែងក្លាយ និងគេចពន្ធដែលមានសារព្រមានរូបភាពជាអក្សរអង់គ្លេសនេះ ដោយបានចាប់បញ្ជូនជនល្មើស និងកសាងសំណុំរឿងនៅតុលាការ។ ដោយឡែកករណីផលិតផលក្លែងក្លាយនេះ ដែលគ្មានសារព្រមានសុខភាពជារូបភាព ដែលជាផលិតផលក្លែងក្លាយគេពន្ធនេះ ក៏ជាប្រធានបទមួយដែលបានពិភាក្សានៅក្នុងក្រុមការងារ “ឃ” នៃវេទិកាសាធារណៈ និងឯកជនដែលមាន ឯកឧត្តម **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ជាសហប្រធាន ដែលក្នុងនោះមានតំណាងក្រសួងសុខាភិបាលជាសមាជិកផងដែរ ហើយគណៈកម្មការចម្រុះនៃអគ្គនាយកដ្ឋានពន្ធដា និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក៏ត្រូវបានបង្កើតឡើងដើម្បីចាត់វិធានការណ៍លើផលិតផលដែលពុំមានសារព្រមានសុខភាពជារូបភាពនេះ រួមទាំងផលិតផលបារីម៉ាក៥៥៥ ដែលមានសារព្រមានសុខភាពជាភាសារអង់គ្លេសនេះផងដែរ។ ផលិត ផលបារីម៉ាក៥៥៥ ដែលមានសារព្រមានសុខភាពជាភាសារអង់គ្លេស និងពុំមានបិទតែមប្រើអាករនេះ ជាផលិតផលបារីក្លែងក្លាយ និងគេចពន្ធ ដែលកន្លងមកគណៈកម្មការប្រយុទ្ធប្រឆាំងទំនិញក្លែងក្លាយ រហូតដល់ចាប់បានជនដែលល់ និងបិទរោងចក្រនៅក្នុងខេត្តកំពង់ស្ពឺ ដែលរឿងក្តីនេះកំពុងស្ថិតក្រោមចំណាត់ការរបស់គណៈកម្មការប្រយុទ្ធប្រឆាំងទំនិញក្លែងក្លាយ និងសាលាដំបូងខេត្តកំពង់ស្ពឺនៅឡើយ។ សរុបមក ផលិតផលបារីម៉ាក៥៥៥ ដែលមានសារព្រមានសុខភាពជាភាសារអង់គ្លេស និងមិនមានបិតតែមប្រើអាករ ជាផលិតផលបារីក្លែង មិនមែនជាផលិតផលរបស់ក្រុមហ៊ុន BRITISH AMERICAN TOBACCO (CAMBODIA) LIMITED ឡើយ។ ឆ្លៀតឱកាសនេះ យើងខ្ញុំសុំស្នើដល់តុលាការ ជាពិសេសក្រសួងសុខាពិបាលមេត្តាចាត់វិធានការលើទំនិញក្លែងក្លាយគេចពន្ធនេះ ដោយចាត់វិធានការតឹងរឹងលើអ្នកលួចផលិត និងនាំចូល។ ករណីនេះគឺកូនក្តីយើងខ្ញុំជាជនរងគ្រោះសុទ្ធសាធ ហើយខាតបង់យ៉ាងធ្ងន់ធ្ងរ ដោយសារផលិតផលក្លែងក្លាយនេះ។ ឃ-យោងតាមមាត្រា ១១ នៃច្បាប់ស្តីពីការគ្រប់គ្រងផលិតផលថ្នាំជក់ បានបញ្ញត្តិថា “ការផ្សាយពាណិជ្ជកម្ម ផលិតផលថ្នាក់ជក់តាមប្រព័ន្ធផ្សព្វផ្សាយជារូបភាព ឬជាអក្សរ ឬជាសំឡេង តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ស៊ីឌី វីស៊ីឌី ឌីវីឌី សេវាប្រៃសណីយ៍ សេវាទូរគមនាគមន៍ និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ត្រូវហាមឃាត់។ ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជាផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬបណ្ណផ្សព្វផ្សាយ ផលិតផលថ្នាំជក់ផ្សេងៗទៀតជាសាធារណៈ និងការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជារូបភាពចល័ត នៅលើជញ្ជាំងយន្ត ឬលើយានជំនិះ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទត្រូវហាមឃាត់ ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ដល់សាធារណៈជននៅតាមទីកន្លែងសាធារណៈណាមួយដូចជាក្នុងកម្មវិធីប្រគំតន្ត្រី ឬកម្មវិធីផ្សេងទៀត និងការ

លើកកម្ពស់ការផ្សព្វផ្សាយផលិតផលថ្នាំជក់ដល់អតិថិជនដោយផ្ទាល់ ឬដោយប្រយោលដោយ ភ្នាក់ងារក្រុមហ៊ុនផលិតថ្នាំជក់ត្រូវហាមឃាត់។" ការហាមឃាត់នៃមាត្រា ១១ គឺមានន័យថាសម្ភារៈដែលត្រូវចាត់ទុកថាជា "ការផ្សព្វផ្សាយពាណិជ្ជកម្ម" និងជាការផ្សាយពាណិជ្ជកម្ម គឺលុះត្រាតែសម្ភារៈទាំងអស់នៅដាក់តាំងនៅតាមទីសាធារណៈ ដែលអាចចាត់ទុកថាជា "ការផ្សព្វផ្សាយពាណិជ្ជកម្ម" គឺសម្ភារៈផ្សាយគួរត្រូវមានម៉ាកយីហោ និមិត្តសញ្ញា ឬសញ្ញានៃម៉ាកយីហោនៃផលិតផល ដែលអាចធ្វើអោយអតិថិជនធ្វើការបែងចែកច្បាស់លាស់ថាសម្ភារៈនេះជាផលិតផលពិតប្រាកដមួយ។ ចុះប្រសិនបើអតិថិជនមិនអាចបែកចែក ឬកត់សម្គាល់នូវសម្ភារៈមួយ ថាជាផលិតផលមួយណាផង តើអាចនិយាយនេះជាការផ្សាយពាណិជ្ជកម្មទេ? ជារួមមាត្រា ១១ នេះ មិនមានគោលបំណងក្នុងការហាមនូវការផ្តល់ព័ត៌មានអំពីផលិតផលឡើយ ជាពិសេសការផ្តល់ព័ត៌មានអំពីផលិតផលពីរោងចក្រ ពីអ្នកនាំចូលទៅដល់ដៃគូពាណិជ្ជកម្ម អ្នកលក់រាយ ដើម្បីឲ្យដៃគូពាណិជ្ជកម្ម អ្នកលក់រាយ បានយល់អំពីព័ត៌មានអំពីផលិតផល អំពីតម្លៃ ហើយព័ត៌មានដើម្បីបែងចែក និងសំគាល់នូវផលិតផលផ្សេងៗគ្នា នៃផលិតថ្នាំជក់របស់ខ្លួនឡើយ។ ង-កន្លងមកក្រុមហ៊ុន BRITISH AMERICAN TOBACCO (CAMBODIA) LIMITED មិនមានការធ្វើការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំ ជក់តាមប្រព័ន្ធផ្សព្វផ្សាយជារូបភាព ឬជាអក្សរ ឬជាសំឡេង តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ស៊ីឌី វីស៊ីឌី ឌីវីឌី សេវាប្រៃសណីយ៍ សេវាទូរគមនាគមន៍ និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតឡើយ លើសពីនេះទៅទៀត ក្រុមហ៊ុនមិនមានការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជាផ្ទាំងរូបភាព ផ្ទាំងប៉ាណូផ្ទាំងបដា ផ្ទាំងគំនូរ ឬបណ្ណផ្សព្វផ្សាយ ផលិតផលថ្នាំជក់ផ្សេងៗទៀតជាសាធារណៈ និងការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជារូបភាពចល័តនៅលើជញ្ជាំងយន្ត ឬលើយានជំនិះ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទឡើយ ហើយក្រុមហ៊ុនក៏មិនមានការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ដល់សាធារណៈជននៅតាមទីកន្លែងសាធារណៈណាមួយដូចជា ក្នុងកម្មវិធីប្រគំតន្ត្រី ឬកម្មវិធីផ្សេងទៀត និងការលើកកម្ពស់ការផ្សព្វផ្សាយផលិតផលថ្នាំជក់ដល់អតិថិជនដោយផ្ទាល់ ឬដោយប្រយោលដោយភ្នាក់ងារក្រុមហ៊ុនផលិតថ្នាំជក់ផងដែរ។ ប៉ុន្តែកន្លងមកក្រុមហ៊ុនមានការធ្វើការទំនាក់ទំនងផ្តល់ព័ត៌មានអំពីផលិតផលទៅដល់អ្នកលក់រាយតាមរយៈសម្ភារៈមួយចំនួន ដោយមានបញ្ជាក់ច្បាស់ថា រាល់ការទំនាក់ទំនងទាក់ទងផ្តល់ព័ត៌មានអំពីផលិតផលនេះ គឺធ្វើឡើងសម្រាប់តែអ្នកលក់រាយតែប៉ុណ្ណោះ ដោយពុំមានបំណងធ្វើឡើងដោយផ្ទាល់ ឬប្រយោងទៅកាន់អតិថិជន ដែលជាអ្នកជក់នោះឡើយ។ លើលពីនេះទៅទៀត ក្រុមហ៊ុនមានភ្នាក់ងារលក់ដោយមានប្រើប្រាស់ឯកសណ្ឋាន ដោយមិនមានបោះពុម្ពម៉ាកយីហោផលិតផលបារីណាមួយរបស់ក្រុមហ៊ុន ក្នុងបំណងផ្សាយពាណិជ្ជកម្មឡើយ ពួកគាត់គឺជាភ្នាក់ងារលក់ផលិតផលបារីសុទ្ធសាធ ហើយដែលឯកសណ្ឋាននេះ គឺជាឯកសណ្ឋានរបស់ក្រុមហ៊ុនសុទ្ធសាធ។ **៣-ធាតុផ្សំសត្យានុម័តៈ ក-**យោងតាមអង្គហេតុដែលលើកឡើងខាងលើ ក្រុមហ៊ុនមិនមានធាតុផ្សំសត្យានុម័ត ដែលបញ្ជាក់ថាបានប្រព្រឹត្តខុសទៅនឹងមាត្រា ៩ ,មាត្រា ១០ និងមាត្រា ១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់នោះទេ។ ទាក់ទងទៅនឹងការចោទ

ប្រកាន់តាមមាត្រា ៩ នៃច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលថ្នាំជក់នេះ ក្រុមហ៊ុនមិនបានធ្វើការបោះពុម្ពនូវពាក្យពេជន៍ណាមួយដែលហាមឃាត់ដោយមាត្រា ៩ នេះ នៅលើរាល់ផលិតផល ថ្នាំជក់របស់ក្រុមហ៊ុននេះទេ ហើយរូបភាពដែលផ្ទាំងរូបភាពបារីសេកបិទនៅលើទូបារីថតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ដែលមានបង្ហាញនៅក្នុងពាក្យសុំបញ្ចូលភស្តុតាងលេខ **៣២១/២០** របស់ការិយាល័យមេធាវី **វ៉ន អេស៊ា** ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ គឺជាគឺផ្ទាំងរូបភាពនៅលើទូបារី មិនមែនជាពាក្យពេជន៍ដែលបោះពុម្ពនៅ លើកញ្ចប់បារីនោះទេ។ ដូចនេះផ្ទាំងរូបភាពទាំងនេះ មិនអាចចាត់ទុកថារំលោភបំពានទៅលើមាត្រា ៩ នោះទេ ដោយមិនចាំបាច់វិភាគអត្ថន័យនៃពាក្យពេជន៍ទាំងនោះឡើយ។ ហើយការវិភាគថាតើផ្ទាំងរូបភាពនេះមានអនុលោមភាព ឬអត់គឺគួរតែធ្វើការវិភាគវាយតម្លៃតាមមាត្រា ១១។ ទាក់ទងទៅនឹងការចោទប្រកាន់តាមមាត្រា ១០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលថ្នាំជក់នេះ ក្រុមហ៊ុនមិនមានការផលិត ឬនាំចូលនូវផលិតផលថ្នាំជក់ដែល មិនមានសារព្រមានសុខភាពជារូបភាព និងអក្សរខ្មែរ និងមិនមានបិទតែមប្រើនោះទេ គ្រប់ផលិតផលរបស់ក្រុមហ៊ុន គឺមានបោះពុម្ពសារព្រមានសុខភាពជារូបភាព និងបិតតែមប្រើអាករ។ ផលិតផលដែលមានសារព្រមានសុខភាពជាភាសារអង់គ្លេស ហើយពុំមានបោះពុម្ពតែមប្រើអាករនេះ ជាផលិតផលក្លែងក្លាយគេចពន្ធ ដែលត្រូវបានជនខិតខូចលួចផលិត និងលួចនាំចូលដោយខុសច្បាប់ ហើយក្រុមហ៊ុនក៏បានស្នើសុំកិច្ចអន្តរាគមន៍ទៅវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន និងស្ថាប័នមានសមត្ថកិច្ចដើម្បីចាត់វិធានការទប់ស្កាត់ និងរឹបអូសផលិតផលបារី៥៥៥ ក្លែងក្លាយ និងគេចពន្ធនេះផងដែរ។ ផលិតផលបារី ៥៥៥ ដែលមានសារព្រមានសុខភាពជាភាសាអង់គ្លេស ដែលតាំងបង្ហាញលក់នៅក្នុងធុងបារីថតនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ដែលមានបង្ហាញនៅក្នុងក្នុងពាក្យសុំបញ្ចូលភស្តុតាងលេខ ៣២១/២០ របស់ការិយាល័យមេធាវី **វ៉ន អេស៊ា** ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ គឺមិនមែនជាផលិតផលរបស់ក្រុមហ៊ុន ដែលកូនក្តីរបស់យើងខ្ញុំឡើយ ព្រោះពុំមានបោះពុម្ពសារព្រមានសុខភាពជារូបភាព ៥០% និងអក្ស៥% និងបោះពុម្ពតែមប្រើអាករនៅកញ្ចប់ទាំងនោះឡើយ។ ទាក់ទងទៅនឹងការចោទប្រកាន់តាមមាត្រា ១១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលថ្នាំជក់នេះ ចំពោះរូបភាពនៃសម្ភារៈផ្ដល់ព័ត៌មានអំពីផលិតផល សម្ភារៈទាំងអស់នេះពុំមានភ្ជាប់ជាមួយនឹងម៉ាកសញ្ញា និមិត្តសញ្ញា ឬសញ្ញាសំគាល់ នៃម៉ាកយីហោរបស់ផលិតផលថ្នាំជក់ ឬដើម្បីធ្វើការបង្ហាញនូវផលិតផលថ្នាំជក់ណាមួយដែរ ហើយដូច្នេះ រូបភាពទាំងនេះមិនគួរត្រូវបានចាត់ទុកថាគឺជា "ការផ្សព្វផ្សាយពាណិជ្ជកម្ម" នៅក្រោមមាត្រា ១១ នោះដែរ។ សម្ភារៈទាំងអស់នេះគឺសម្រាប់ធ្វើការផ្ដល់ព័ត៌មានអំពីផលិតផលទៅដល់អ្នកលក់រាយ ដែលបានបញ្ជាក់ច្បាស់ថា សម្ភារទាំងនោះគឺ "សម្រាប់តែអ្នកលក់រាយតែប៉ុណ្ណោះ"។ ក្រុមហ៊ុនបានផ្ដល់នូវសម្ភារៈទាំងនោះទៅឱ្យអ្នកលក់រាយ ហើយអ្នកលក់រាយដាក់បង្ហាញដោយខ្លួនឯង។ ចំពោះរូបភាពនៃបុគ្គលិកផ្នែកលក់របស់ក្រុមហ៊ុន ដែលកំពុងលក់នៅក្នុងទីផ្សារ នៅក្នុងទីផ្សារដែលបានដាក់ជូនជាភស្តុតាង ភ្ជាប់នឹងពាក្យបណ្ដឹងរបស់ក្រសួងសុខាភិបាល ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ គឺជាបុគ្គលិកផ្នែកលក់របស់ក្រុមហ៊ុន ហើយឯកសណ្ឋានរបស់ពួកគាត់ មិនមានបោះពុម្ពនូវម៉ាក

សញ្ញា និមិត្តសញ្ញា សញ្ញាសំគាល់ម៉ាកយីហោ ឬបង្ហាញពីផលិតផលណាមួយឡើយ ដូចនេះរូបភាពទាំងនេះមិនគួរត្រូវបានគិតថាជាការផ្សព្វផ្សាយពាណិជ្ជកម្ម ដូចមានចែងនៅក្នុងប្រការ ១១ នោះទេ។ អាវយឺតទាំងអស់នេះគឺជាឯកសណ្ឋានសម្រាប់បុគ្គលិកផ្នែកលក់ និងបុគ្គលិករបស់ក្រុមហ៊ុនដែលគ្រប់ក្រុមហ៊ុនទាំងអស់ដែលក្រុមហ៊ុនលក់ផលិតផល និងផ្តល់សេវាកម្មតែងតែមានឯកសណ្ឋានសម្រាប់បុគ្គលិក និងភ្នាក់ងារលក់របស់ខ្លួនយ៉ាងដូចនេះជានិច្ច។ លើសពីនេះទៅទៀត ចំពោះផ្ទាំងរូបភាពបារីសេកព្យួរនៅតូបគ្រឿងទេសថតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២០ និងថតថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ ផ្ទាំងរូបភាពបារីសេកបិទនៅលើទូបារីថតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ និងថតនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២០ ដែលមានបង្ហាញនៅក្នុងក្នុងពាក្យសុំបញ្ចូលភស្តុតាងលេខ **៣២១/២០** របស់ការិយាល័យមេធាវី **វ៉ន អេស៊ា** ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ គឺពុំមានបោះពុម្ពនូវម៉ាកសញ្ញា និមិត្តសញ្ញា សញ្ញាសំគាល់ម៉ាកយីហោ ឬបង្ហាញពីផលិតផលណាមួយឡើយ ដូចនេះរូបភាពទាំងនេះមិនគួរត្រូវបានគិតថាជាការផ្សព្វផ្សាយពាណិជ្ជកម្ម ដូចមានចែងនៅក្នុង ប្រការ ១១ នោះទេ។ សម្ភារៈទាំងនេះគឺសម្រាប់ផ្តល់នូវព័ត៌មានអំពីផលិតផលរបស់ក្រុមហ៊ុនទៅកាន់អ្នកលក់រាយ ហើយដែលមានគឺប្រើប្រាស់ពាក្យថា "សំរាប់តែអ្នកលក់រាយប៉ុណ្ណោះ"។ ក្រុមហ៊ុនបានផ្តល់នូវសម្ភារៈទាំងនោះទៅឱ្យអ្នកលក់រាយ ហើយអ្នកលក់រាយដាក់បង្ហាញដោយខ្លួនឯង។ ជារួមពុំមានព្យសនកម្មណាមួយ ដែលកើតចេញពីសកម្មភាពខាងលើនោះទេ ផ្ទុយទៅវិញក្រុមហ៊ុន BRITISH AMERICAN TOBACCO (CAMBODIA) LIMITED ដែលជាកូនក្តីយើងខ្ញុំជាជនរងគ្រោះទៅវិញទេ ជាពិសេសចំពោះការចោទប្រកាន់តាមមាត្រា ១០ នៃច្បាប់ច្បាប់ស្តីពីការត្រួតផលិតផលថ្នាំជក់នេះ។ **៤-ធាតុផ្សំអត្តនោម័តៈ** ក-ផ្អែកតាមអង្គហេតុធាតុផ្សំនីត្យានុកូល និងធាតុផ្សំសត្យានុម័ត អាចបញ្ជាក់បានថាក្រុមហ៊ុន BRITISH AMERICAN TOBACCO (CAMBODIA) LIMITED មិនមានចេតនាទុច្ចរិតណាមួយប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់ឯកឧត្តមវេជ្ជ **អ៊ឹង ភីរុន** តំណាងឱ្យក្រសួងសុខាភិបាលនោះទ។ **៥-សេចក្តីសន្និដ្ឋាន** ឆ្លងតាមការបកស្រាយទាំងអង្គហេតុ ធាតុផ្សំនៃបទល្មើស និងទឡ្ហីករណ៍ខាងលើនេះ យើងខ្ញុំជាមេធាវីការពារសិទ្ធិឱ្យក្រុមហ៊ុន សូមសំណូមពរ ឯកឧត្តមប្រធាន មេត្តាសម្រេចឱ្យក្រុមហ៊ុន BRITISH AMERICAN TOBACCO (CAMBODIA) LIMITED រួចផុតពីបទល្មើសដែលត្រូវបានចោទប្រកាន់តាមមាត្រា ៨ ,មាត្រា ១០ ,មាត្រា ១១ ,មាត្រា ៣៩ ,មាត្រា ៤០ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់ នៃព្រះរាជាណាចក្រកម្ពុជា។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានពាក្យបណ្តឹងរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **៤៨៤៨** ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ មកជំនុំជម្រះដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ **០៥៦ អ.យ.ឃ** ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ **ប៊ុន រតន៍លីដា** ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន British American Tobacco (Cambodia) Ltd មកជំនុំជម្រះពីបទ **ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩ ,មាត្រា ១១ ,មាត្រា ៣៩ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

២-តាមអំណាចចម្លើយជនជាប់ចោទឈ្មោះ **ប៊ុន រតន៍លីដា** បានឆ្លើយនៅដំណាក់កាលអយ្យការថា: ចំពោះការលើកឡើងរបស់ក្រសួងសុខាភិបាលដែលបានចោទប្រកាន់ក្រុមហ៊ុនរបស់ខ្លួនថា បានឱ្យបុគ្គលិកចុះធ្វើការផ្សព្វផ្សាយផលិតផលបារីម៉ាក៥៥៥ នៅទីសាធារណៈនោះ គឺមិនពិតប្រាកដឡើយ ដោយសាររូបភាពបុគ្គលិករបស់ក្រុមហ៊ុនខ្លួនដែលមាននៅក្នុងភស្តុតាងនេះ មិនមែនជាបុគ្គលិកចុះផ្សព្វផ្សាយនោះឡើយ គឺជាភ្នាក់ងារលក់របស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយឯកសណ្ឋានរបស់បុគ្គលិកទាំងអស់នោះក៏មិនបានបង្ហាញអំពីរូបភាពផលិតផលបារី ដែលធ្វើឱ្យមានការទាក់ទាញដល់សាធារណៈជននោះឡើយ។ ចំពោះការប្រគល់រង្វាន់ ខ្លួនទទួលស្គាល់ថាក្រុមហ៊ុនពិតជាបានប្រគល់រង្វាន់ដល់អតិថិជនប្រាកដមែន ប៉ុន្តែអតិថិជនទាំងអស់នោះគឺជាអ្នកលក់បោះដុំនូវផលិតផលរបស់ក្រុមហ៊ុនខ្លួនតែប៉ុណ្ណោះ មិនមែនជាការផ្តល់រង្វាន់ដល់អ្នកប្រើប្រាស់ផ្ទាល់ឡើយ ចំណែកការប្រគុំតន្ត្រីដូចមាននៅក្នុងរូបភាពជាភស្តុតាងនោះ គឺគ្រាន់តែជាពិធីជប់លៀងលើកទឹកចិត្តដល់អតិថិជនទទួលបោះដុំពីក្រុមហ៊ុន ហើយការរៀបចំនេះក៏គ្រាន់តែជាការជួបជុំជាលក្ខណៈឯកជនរបស់ក្រុមហ៊ុនស្ថិតក្នុងទីតាំងបិទជិតដោយមានការចូលរួមពីដៃគូសហការ និងអ្នកលក់បោះដុំពុំមែនធ្វើឡើងជាសាធារណៈនោះទេ។ ក្នុងរឿងនេះក្រុមហ៊ុនរបស់ខ្លួនមិនធ្លាប់ទទួលបានលិខិតអញ្ជើញ ដើម្បីចូលរួមដោះស្រាយ ឬលិខិតព្រមានពីក្រសួងសុខាភិបាលឡើយ ចំណែកអាជ្ញាធរមានសមត្ថកិច្ចក៏មិនបានធ្វើការដកហូតផលិតផលរបស់ក្រុមហ៊ុននោះដែរ ហើយកន្លងមកក្រុមហ៊ុនរបស់ខ្លួនតែងតែគោរពតាមច្បាប់តឹងតែងបំផុត ដែលជាហេតុមិនដែលមានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យ និងដកហូតផលិតផលរបស់ក្រុមហ៊ុនខ្លួនឡើយ ដោយសារតែផលិតផលមានច្បាប់អនុញ្ញាតត្រឹមត្រូវ ហើយការផលិត និងការវេចខ្ចប់សុទ្ធតែគោរពទៅតាមការកំណត់របស់ច្បាប់ទាំងអស់ ដូចជាការដាក់រូបភាពបង្ហាញពីផលប៉ះពាល់លើកញ្ចប់បារី និងសារព្រមានជាដើម ចំណែកឯផលិតផលដែលមានដាក់សារព្រមានជាភាសារអង់គ្លេស (SMOKING KILLS) គឺជាផលិតផលក្លែងក្លាយ ហើយក្រុមហ៊ុន

របស់ខ្លួនក៏បានដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការតាមច្បាប់រួចរាល់អស់ហើយ។ ចំពោះភស្តុតាងជារូបភាពដែលបង្ហាញអំពីពាក្យទាក់ទាញដូចជាពាក្យថា "ភាពស្រស់ស្រាយ នៃរស់ជាតិរបស់កម្ពុជា ,ចុចកន្ទុយបារីដើម្បីបង្កើតភាពស្រស់ស្រាយ និងរសជាតិនៃភាពស្រទន់" នៅលើទូលក់បារី និងក្រដាស់ចងខ្សែ ដូចមានក្នុងពាក្យសុំបញ្ចូលភស្តុតាង ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់លោកមេធាវី **សែម ស៊ីនរិទ្ធ** និងលោកមេធាវី **កឹម វឌ្ឍនៈ** ជាមេធាវីការពារក្ដី និងតំណាងដោយអាណត្តិឱ្យក្រសួងសុខាភិបាលនោះ គឺជាសម្ភារៈរបស់ក្រុមហ៊ុន ហើយក្រុមហ៊ុនបានប្រគល់សម្ភារៈទាំងអស់នេះដល់អតិថិជនលក់រាយ ប៉ុន្តែការដាក់ពាក្យទាំងអស់នេះ គឺមានតែនៅលើទូលក់បារី និងក្រដាសចងខ្សែប៉ុណ្ណោះ មិនបានដាក់នៅលើផលិតផលរបស់ក្រុមហ៊ុនឡើយ និងពុំមានបង្ហាញម៉ាកយីហោរបស់ផលិតផលឡើយ។

៣-តាមអំណានពាក្យបណ្ដឹងរបស់ក្រសួងសុខាភិបាល ដែលតំណាងស្របច្បាប់ដោយ ឯកឧត្តមវេជ្ជបណ្ឌិត **អ៊ឹង ភីរុន** ជារដ្ឋលេខាធិការក្រសួងសុខាភិបាល បានបញ្ជាក់ថា: កន្លងមកក្រុមហ៊ុន British American Tobacco (Cambodia) Ltd. ដែលជាក្រុមហ៊ុនលក់ផលិតផលថ្នាំជក់ បានធ្វើការផ្សព្វផ្សាយផលិតផលថ្នាំជក់របស់ខ្លួននៅទីសាធារណៈ ជាលក្ខណៈផ្ទាំងរូបភាពពាណិជ្ជកម្មនៃផលិតផលថ្នាំជក់ ដែលបោះពុម្ពនៅលើអាវរបស់ភ្នាក់ងារបុគ្គលិករបស់ខ្លួន។ មិនតែប៉ុណ្ណោះក្រុមហ៊ុននេះ បានធ្វើការលើកកម្ពស់ការផ្សព្វផ្សាយផលិតផលថ្នាំជក់ដល់អតិថិជន ដោយក្រុមហ៊ុននេះបានឱ្យភ្នាក់ងារបុគ្គលិកពាក់អាវដែលមានផ្ទាំងរូបភាពនោះ ចុះទៅផ្សព្វផ្សាយតាមភោជនីយដ្ឋាន និងទីសាធារណៈ ដែលជាសកម្មភាពត្រូវបានហាមឃាត់ក្នុងការផ្សព្វផ្សាយផលិតផលថ្នាំជក់។ ម្យ៉ាងទៀតក្រុមហ៊ុននេះក៏បានធ្វើការផ្សព្វផ្សាយផលិតផលរបស់ខ្លួនតាមរយៈការប្រគុំតន្ត្រី និងមានការផ្ដល់រង្វាន់ដូចជា ទូរស័ព្ទដៃថែមទៀតផង ដែលការផ្សព្វផ្សាយក្នុងកម្មវិធីជាសាធារណៈបែបនេះ គឺច្បាប់ពុំអនុញ្ញាតជាដាច់ខាត។ ក្រសួងសុខាភិបាលក៏បានធ្វើការព្រមានក្រុមហ៊ុននេះរួចហើយដែរ ប៉ុន្តែក្រុមហ៊ុននេះនៅតែមិនគោរពតាមច្បាប់ និងការព្រមានរបស់ក្រសួងសុខាភិបាលទៀត។ យោងតាមសកម្មភាពខាងលើ គឺក្រុមហ៊ុននេះមានចេតនាទុច្ចរិតក្នុងការផ្សព្វផ្សាយផលិតផលរបស់ខ្លួន ដើម្បីទទួលបានការចាប់អារម្មណ៍ពីអ្នកប្រើប្រាស់ឱ្យកាន់តែច្រើនដើម្បីទទួលបានផលប្រយោជន៍ឯកជនដោយមិនគិតពីច្បាប់ ។ សកម្មភាពដែលក្រុមហ៊ុននេះបានប្រព្រឹត្ត ជាសកម្មភាពដែលបំពានទូវច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ហើយការផ្សព្វផ្សាយបែបនេះអាចជម្រុញឱ្យមានការប្រើប្រាស់ថ្នាំជក់កាន់តែច្រើន និងអាចនាំឱ្យមានផលប៉ះពាល់ដល់សុខភាពប្រជាជន និងសុខភាពសាធារណៈដែលច្បាប់ព្យាយាមការពារផងដែរ ។

៤-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ **ប៊ុន រតន៍លីដា** ,អំណានពាក្យបណ្ដឹងរបស់ក្រសួងសុខាភិបាល និងភស្តុតាងនានានៅក្នុងសំណុំរឿង ឃើញថា ក្រុមហ៊ុន British American Tobacco (Cambodia)Ltd និងឈ្មោះ **ប៊ុន រតន៍លីដា** ដែលជាប្រធានក្រុមហ៊ុន British American Tobacco (Cambodia)Ltd បានធ្វើសកម្មភាពផ្សព្វផ្សាយផលិតផលពីថ្នាំជក់របស់ខ្លួននៅទីសាធារណៈ ជាលក្ខណៈផ្ទាំងរូបភាពពាណិជ្ជកម្មនៃ

ផលិតផលថ្នាំជក់នៅលើអាវរបស់ភ្នាក់ងារបុគ្គលិករបស់ខ្លួន និងចុះទៅផ្សព្វផ្សាយតាមភោជនីយដ្ឋាន និងទីសាធារណៈ ម្យ៉ាងទៀតថែមទាំងបានធ្វើការផ្សព្វផ្សាយផលិតផលរបស់ខ្លួនតាមរយៈការប្រគំតន្ត្រី និងមានការផ្តល់រង្វាន់ជាទូរស័ព្ទដៃថែមទៀតផង ដែលនេះជាសកម្មភាពត្រូវបានហាមឃាត់ក្នុងការផ្សព្វផ្សាយផលិតផលថ្នាំជក់ ពិតប្រាកដមែន។

៥-អំពើរបស់ជនជាប់ចោទឈ្មោះ **ប៊ុន រតន៍លីដា** ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន British American Tobacco (Cambodia) Ltd ដែលបានធ្វើសកម្មភាពផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយបោះពុម្ពផ្សាយនៅលើអាវរបស់ភ្នាក់ងារបុគ្គលិក ចុះទៅផ្សព្វផ្សាយតាមភោជនីយដ្ឋាន និងទីសាធារណៈ ការប្រគំតន្ត្រី ហើយថែមទាំងមានការផ្តល់រង្វាន់ជាទូរស័ព្ទ ដើម្បីទាក់ទាញអតិថិជន គឺជាបទ **ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល**។

៦-ជនជាប់ចោទឈ្មោះ **ប៊ុន រតន៍លីដា** ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន British American Tobacco (Cambodia) Ltd ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្តជននេះមានសមត្ថភាពលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

៧-អំពើរបស់ជនជាប់ចោទឈ្មោះ **ប៊ុន រតន៍លីដា** ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន British American Tobacco (Cambodia) Ltd បានបង្ហាញឱ្យឃើញថា គ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើសជនជាប់ចោទរូបនេះមានចេតនាទុច្ចរិត ដែលការប្រព្រឹត្តទាំងនេះធ្វើអោយប៉ះពាល់ដល់សន្តិសុខសង្គម សណ្តាប់ធ្នាប់សង្គម ប៉ះពាល់ដល់នីត្យានុកូលភាពសង្គមបំពានលើមាត្រា ៩ ,មាត្រា ១១ ,មាត្រា ៣៩ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

៨-មានភស្តុតាង និងមានពិរុទ្ធភាពដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ **ប៊ុន រតន៍លីដា ភេទស្រី** អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន British American Tobacco (Cambodia) Ltd ពីបទ **ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩ ,មាត្រា ១១ ,មាត្រា ៣៩ និងមាត្រា ៤១ នៃច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ។

៩-ជនជាប់ចោទឈ្មោះ **ប៊ុន រតន៍លីដា** ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ តាមជីវប្រវត្តិកន្លងមកជនជាប់ចោទរូបនេះមិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងណាឡើយ គប្បីតុលាការពិចារណាក្នុងការសម្រេចសេចក្តី។

១០-ដើមបណ្តឹងរដ្ឋប្បវេណីក្រសួងសុខាភិបាល ដែលតំណាងស្របច្បាប់ដោយ ឯកឧត្តមវេជ្ជបណ្ឌិត **អ៊ឹង ភីរុន** ជារដ្ឋលេខាធិការក្រសួងសុខាភិបាល បានទាមទារសំណងចំនួន ៤០,០០០,០០០៛ (សែសិបលានរៀល) គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១១-ព្យសនកម្មដែលកើតឡើងដោយសារអំពើរបស់ជនជាប់ចោទឈ្មោះ **ប៊ុន រតន៍លីដា** និងក្រុមហ៊ុន British American Tobacco (Cambodia) Ltd ដូច្នេះជនជាប់ចោទរូបនេះទទួលខុសត្រូវទាំងស្រុងចំពោះការជួសជុលសំណងទៅតាមកំរិត និងព្យសនកម្មដែលកើតឡើង។

១២-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី សុំឲ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ គប្បីតុលាការលើកយកមកពិចារណា។

១៣-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ មានភស្តុតាងគ្រប់គ្រាន់អាចឲ្យតុលាការលើកយកការសន្និដ្ឋានរបស់តំណាងអយ្យការមកពិចារណាក្នុងការសម្រេចសេចក្ដី។

១៤-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សុំឲ្យតុលាការលើកលែងចោទប្រកាន់លើកូនក្ដីខ្លួន ពុំមានភស្តុតាងគ្រប់គ្រាន់អាចឲ្យតុលាការលើកយកមកពិចារណាបានទេ។

## ហេតុដូច្នេះសម្រេច

១-ផ្ដន្ទាទោសឈ្មោះ **ប៊ុន រតន៍លីដា** ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន British American Tobacco (Cambodia) Ltd ពិន័យជាប្រាក់ចំនួន ៣០,០០០,០០០៛ (សាមសិបលានរៀល) រៀលពីបទ **ផ្សព្វផ្សាយផលិតផលថ្នាំជក់ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៩ ,មាត្រា ១១ ,មាត្រា ៣៩ និងមាត្រា ៤១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ។

២-បង្គាប់ឲ្យឈ្មោះ **ប៊ុន រតន៍លីដា** ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ និងក្រុមហ៊ុន British American Tobacco (Cambodia) Ltd រួមគ្នាសងសំណងរដ្ឋប្បវេណី និងជំងឺចិត្ត ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីតំណាងឱ្យក្រសួងសុខាភិបាល ចំនួន ២០,០០០,០០០៛ (ម្ភៃលានរៀល) ។ ការទាមទារលើសពីនេះច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទឈ្មោះ ប៊ុន រតន៍លីដា ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: **ឈិន ឆេង**

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: **ទិត ដាលីន**

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម" ។
ថ្ងៃច័ន្ទ ១១ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២
**ក្រឡាបញ្ជីសវនាការ**

ឈិន ឆេង

បានឃើញ
**ចៅក្រមជំនុំជម្រះ**

ទិត_ដាលីន